មជ្ឈមណ្ឌលឯកសារកម្ពុជា

**PTI0063**

សម្ភាសន៍ជាមួយឈ្មោះ ឈាង ជួ ភេទប្រុស អាយុ៦៥ឆ្នាំ

រស់នៅភូមិប្រម៉ោយ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់

មុខងារសម័យខ្មែរក្រហមៈ វរៈសេនាតូច១២០

មុខងារបច្ចុប្បន្នៈ កសិករ

សម្ភាសន៍ដោយៈ ឡុង ដានី

សម្ភាសន៍ថ្ងៃទី២១ ខែ ខុសភា ឆ្នាំ២០១១

០១:០៣:១៨

សរុបទំព័រៈ ២៩

ដានីៈ អ៊ំជីបូនខ្ញុំចង់ស្គាល់ឈ្មោះអ៊ំ តើឈ្មោះពេញរបស់អ៊ំឈ្មោះអីដែរ?

ជួៈ ខ្ញុំឈ្មោះ ឈាង ជួ ។

ដានីៈ អ៊ំអាយុប៉ុន្មានហើយសព្វថ្ងៃ?

ជួៈ អាយុ៦៥ឆ្នាំ ។

ដានីៈ សព្វថ្ងៃអ៊ំរស់នៅក្នុងភូមិឃុំអីដែរ?

ជួៈ រស់នៅភូមិប្រម៉ោច ឃុំប្រម៉ោច ។

ដានីៈ ស្រុកវាលវែង ខេត្ត?

ជួៈ ខេត្តពោធិ៍សាត់ ។

ដានីៈ ប្រពន្ធរបស់ពូឈ្មោះអីដែរ?

ជួៈ ឈ្មោះ អ៊ុច នៀត ។

ដានីៈ គាត់អាយុប៉ុន្មានហើយ?

ជួៈ អាយុ៦០ឆ្នាំ ។

ដានីៈ អ៊ំមានកូនចៅទាំងអស់ប៉ុន្មាននាក់ដែរ?

ជួៈ ខ្ញុំមានកូនចៅទាំងអស់៣នាក់ ។

ដានីៈ ស្រីប៉ុន្មានហើយប្រុសប៉ុន្មាន?

ជួៈ ស្រី១ ហើយប្រុស២នាក់ ។

ដានីៈ អ៊ំស្រុកកំណើតកើតនៅណាដែរ?

ជួៈ នៅភូមិជ្រៃ ឃុំព្រៃស្រឡឹក ។

ដានីៈ ស្រុក?

ជួៈ ស្រុកពារាំង ។

ដានីៈ ខេត្តព្រៃវែង?

ជួៈ បាទ!

ដានីៈ ឪពុករបស់អ៊ំឈ្មោះអីទៅ?

ជួៈ គាត់ស្លាប់ហើយ ។

ដានីៈ តែគាត់ឈ្មោះអីទៅ?

ជួៈ ឈ្មោះ ហេង ឈាង ។

ដានីៈ គាត់ស្លាប់តាំងពីអង្កាល់?

ជួៈ ស្លាប់ប្រហែលជាចូល៥០ឆ្នាំហើយ ។

ដានីៈ ប្រហែលជា៥០ឆ្នាំជាងហើយ?

ជួៈ បាទ!

ដានីៈ ចុះម្តាយ?

ជួៈ ម្តាយឈ្មោះ អ៊ួង ហ៊ាន ។

ដានីៈ គាត់នៅរស់ឬក៏ស្លាប់អស់ហើយ?

ជួៈ គាត់ស្លាប់អស់ហើយ ។

ដានីៈ គាត់ស្លាប់ពីអង្កាល់ដែរ?

ជួៈ គាត់ស្លាប់ប្រហែលជា១០ឆ្នាំហើយ ។

ដានីៈ ចុះបងប្អូនបង្កើតរបស់អ៊ំមានប៉ុន្មាននាក់ដែរ?

ជួៈ បងប្អូបង្កើតរបស់ខ្ញុំមានតែ៤នាក់ទេ ។

ដានីៈ ហើយស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ជួៈ ស្រី១ ប្រុស៣នាក់ ។

ដានីៈ អ៊ំកូនទីប៉ុន្មាន?

ជួៈ ខ្ញុំកូនទី១ ។

ដានីៈ អ៊ំកាលពីក្មេងរៀនសូត្រដល់ថ្នាក់ណាដែរ?

ជួៈ កាលនៅក្មេងខ្ញុំរៀនបានត្រឹមថ្នាក់ទី៧ ។

ដានីៈ រៀនដល់ថ្នាក់ទី៧?

ជួៈ ទី៧ចាស់ ។

ដានីៈ រៀននៅសាលាណាដែរ?

ជួះ នៅសាលាជ្រៃហ្នឹង ។

ដានី៖ សាលាជ្រៃនៅក្នុងភូមិជ្រៃហ្នឹង?

ជួះ បាទ!

ដានី៖ ចុះបន្ទាប់ពីអ៊ំឈប់រៀនអ៊ំធ្វើអីទៀតទៅ?

ជួះ ខ្ញុំធ្វើស្រែ ។

ដានី៖ ពេលឈប់រៀនធ្វើស្រែ?

ជួះ បាទ!

ដានី៖ ឈប់រៀននៅឆ្នាំណា?

ជួះ នៅឆ្នាំ ប្រហែលជាឆ្នាំ៦២ ។

ដានី៖ ហើយមូលហេតុអីបានជាអ៊ំរៀនដល់ថ្នាក់ទីប៉ុណ្ណឹងហើយឈប់រៀន?

ជួះ ឪពុកខ្ញុំគាត់ស្លាប់ទៅ នៅម៉ែគាត់ក្រ ហើយមិនដឹងម៉េចមានតែឈប់ហ្នឹងហើយ នៅឃ្វាលគោឃ្វាលក្របីហ្នឹង ។

ដានី៖ អញ្ចឹងដល់ពេលឈប់ទៅ មកនៅធ្វើស្រែជាមួយម្ដាយ?

ជួះ បាទ!

ដានី៖ កាលហ្នឹងឪពុកអ៊ំគាត់នៅទេ?

ជួះ ម៉ែនៅរស់ ។

ដានី៖ ចុះអ៊ំនៅឃ្វាលគោ ឃ្វាលក្របី ធ្វើស្រែចំការរហូតដល់ឆ្នាំណាទៅ?

ជួះ រហូតដល់ឆ្នាំ៧០ ។

ដានី៖ ដល់ឆ្នាំ៧០?

ជួះ ហ្នឹងហើយ ឆ្នាំរដ្ឋប្រហារហ្នឹង ។

ដានី៖ កាលហ្នឹងអ៊ំអត់ទាន់មានប្រពន្ធទេ?

ជួះ នូវ ។

ដានី៖ អញ្ចឹងដល់ពេលរដ្ឋប្រហារឆ្នាំ៧០ហ្នឹង អ៊ំយ៉ាងម៉េចទៀតទៅ?

ជួះ ដល់ពេលរដ្ឋប្រហារឆ្នាំ៧០ហ្នឹងបាតុកម្ម ។

ដានី៖ បាតុកម្មយ៉ាងម៉េចទៅ យ៉ាងម៉េចទៅពេលហ្នឹង?

ជួះ គ្រាន់តែបាតុកម្មហើយ សម្ដេចតាយើងហ្នឹង ព្រះអង្គគាត់ប្រកាសពីបេកាំងមក ឲ្យកូនចៅចូលព្រៃម៉ាគីវៃអាមេរិចកាំងហ្នឹង តស៊ូវៃអាមេរិចកាំង ។

ដានី៖ ហើយម៉េចទៀតទៅអ៊ំ?

ជួៈ ហើយក៏នាំគ្នាចូលទៅ សុទ្ធតែកម្លោះៗដូចគ្នាណា ។

ដានីៈ អញ្ចឹងពេលដែលសម្តេចគាត់ប្រកាសឲ្យតស៊ូ អ៊ំនាំគ្នាចូលតស៊ូ កាលហ្នឹងអ៊ំចូលតស៊ូពីកន្លែងណាទៅកន្លែងណាទៅ?

ជួៈ ខ្ញុំចូលតស៊ូពីចំការលើ ។

ដានីៈ អញ្ចឹងអ៊ំចេញពីស្រុកហើយ?

ជួៈ បាទ! ចេញពីស្រុកហើយ មកនៅចំការលើ ។

ដានីៈ ចេញពីស្រុកឆ្នាំណា?

ជួៈ ចេញពីស្រុកឆ្នាំ៦០ហ្នឹងហើយ ។

ដានីៈ ៧០ឬក៏៦០?

ជួៈ ៦០ មកនៅចំការលើ ។

ដានីៈ អញ្ចឹងអ៊ំចេញពីផ្ទះមកតាំងពីឆ្នាំ៦០ទេ?

ជួៈ បាទ!

ដានីៈ ចុះអ៊ំមានប្រសាសន៍មេញ ថាអ៊ំឈប់រៀនឆ្នាំ៦២?

ជួៈ ហ្នឹងអើយ៦១-៦២ហ្នឹង ប្រហែលជាប៉ុណ្ណឹងហើយ ព្រោះវាយូដែរហើយខ្ញុំភ្លេចចាំហើយ ។

ដានីៈ អញ្ចឹងក៏មកនៅចំការលើ?

ជួៈ បាទ!

ដានីៈ ចុះកាលហ្នឹងម្តាយអ៊ំ?

ជួៈ ម្តាយមេម៉ាយ ។

ដានីៈ ហើយមកនៅចំការលើទាំងអស់គ្នា?

ជួៈ បាទ! បងប្អូនមកនៅចំការលើទាំងអស់គ្នា ។

ដានីៈ អញ្ចឹងផ្លាស់មកនៅចំការលើទាំងអស់គ្នា ហើយមកនៅចំការលើហ្នឹងនៅកន្លែងណា?

ជួៈ ខ្ញុំមកនៅតាំងក្រង ស្វាយទាប ។

ដានីៈ អញ្ចឹងឆ្នាំ៧០អ៊ំមកនៅចំការលើ អ៊ំធ្វើអីទៅ?

ជួៈ ធ្វើស្រែធ្វើចំការទៅ ។

ដានីៈ ធ្វើស្រែធ្វើចំការដដែល?

ជួៈ បាទ!

ដានីៈ រហូតដល់ឆ្នាំ៧០បានអ៊ំចូលតស៊ូ?

ជួៈ បាទ!

ដានីៈ ចូលតស៊ូនៅកន្លែងណា?

ជួៈ ចូលព្រៃម៉ាកគីហ្នឹងជាមួយវៀតណាម ពួកវៀតកុង ។ ។

ដានីៈ ម៉េចបានជាអ៊ំទៅចូលជាមួយពួកវៀតកុង?

ជួៈ ចុះបើវៀតកុងចូលពេញស្រុកពេញដីអស់ហើយ ។

ដានីៈ អញ្ចឹងឆ្នាំ៧០ហ្នឹងវៀតកុងចូលពេញស្រុកពេញដីហើយ?

ជួៈ បាទ!

ដានីៈ អញ្ចឹងអ៊ំចូលចំការលើ ចូលតាំក្រែងហ្នឹងជាមួយវៀតកុង?

ជួៈ បាទ!

ដានីៈ កាលហ្នឹងគ្នាអ៊ំប៉ុន្មាននាក់ដែលចូលទៅជាមួយវៀតកុងហ្នឹង?

ជួៈ ច្រើនណាស់ក្មួយអើយ មិនដឹងប៉ុន្មានទេ ហើយចូលមករាប់រយរាប់ពាន់នាក់ទៅ ហើយវៀតកុងហ្នឹងចេះតែមកៗ ធ្លាយមកដល់កំពង់ឆ្នាំង ។

ដានីៈ មកៗហ្នឹង អញ្ចឹងអ៊ំមកតាមជាមួយវៀតកុងមកដល់កំពង់ឆ្នាំង?

ជួៈ បាទ!

ដានីៈ មកដល់កំពង់ឆ្នាំងឆ្នាំណា?

ជួៈ ឆ្នាំ៧០ហ្នឹងដែរ ។

ដានីៈ កាលអ៊ំនៅជាមួយវៀតកុងហ្នឹង គេហៅអង្គភាពអីគេ?

ជួៈ អត់ស្គាល់ទេ ។

ដានីៈ កាលហ្នឹងអ៊ំមានស្គាល់វៀតកុងខ្លះទេ មានស្គាល់ឈ្មោះវៀតកុងខ្លះទេ?

ជួៈ ដូចភ្លេចហើយក្មួយអើយ ។

ដានីៈ អញ្ចឹងអ៊ំពេលដែលអ៊ំចូលមកនៅជាមួយវៀតកុងហ្នឹង ពួកវៀតកុងគេដើរពីចំការលើហ្នឹងធ្លាក់មកដល់កំពង់ឆ្នាំង?

ជួៈ បាទ!

ដានីៈ អញ្ចឹងគ្នាអ៊ំដែលចូលជាមួយវៀតកុងហ្នឹង មាន១០០មួយរយនាក់ជាង?

ជួៈ បាទ!

ដានីៈ ចូលមកដល់កំពង់ឆ្នាំងហ្នឹងមកនៅកន្លែងណាទៅ?

ជួៈ ចូលមកដល់កន្លែងក្រាំងល្វា ។

ដានីៈ ហើយម៉េចទៀតទៅ?

ជួៈ ដល់អញ្ចឹងទៅ អង្គការខ្មែរយើងណា អ្នកតស៊ូខ្មែរហ្នឹងក៏សុំខ្មែរយើងដែលនៅជាមួយវៀត កុងហ្នឹងចូលមកនៅអង្គភាពខ្មែរ ។

ដានីៈ សុំមកចូលអង្គភាពខ្មែរហ្នឹង គេហៅអង្គភាពអីទៅ?

ជួៈ កងពលទី១ ។

ដានីៈ កងពលទី១?

ជួៈ បាទ! មេខ្ញុំ តាសាន ។

ដានីៈ អ៊ំសាន ហ្នឹងត្រូវជាមេរបស់អ៊ំ?

ជួៈ បាទ!

ដានីៈ ពេលមកដល់ក្រាំងល្វាហ្នឹងគេមានកងពលដែរ?

ជួៈ នៅទេ មិនទាន់កើតជាកងពលទេ គ្រាន់តែបង្កើតជាវរៈសេនាតូចហ្នឹង វរៈសេនាតូចច្រើន ដែរហ្នឹង ។

ដានីៈ កាលហ្នឹងអ៊ំនៅជាមួយពីណាខ្លះ កាលនៅក្រាំងល្វា?

ជួៈ ខ្ញុំនៅជាមួយមេៗ តែគាត់ស្លាប់អស់ហើយ នៅតែមួយគឺអ៊ំ សាន ហ្នឹងហើយ ។

ដានីៈ គាត់ធ្វើអី?

ជួៈ កាលហ្នឹងគាត់វរៈសេនាតូច ។

ដានីៈ គាត់ប្រធានវរៈសេនាតូច?

ជួៈ មានគេទៀត ។

ដានីៈ អញ្ចឹងតួនាទីគាត់អីគេ?

ជួៈ គាត់បែបអនុបញ្ជាការហ្នឹង ។

ដានីៈ ហើយចុះអ៊ំ កាលហ្នឹងអ៊ំមានតួនាទីអីដែរ?

ជួៈ ខ្ញុំមានយុទ្ធជនហ្នឹង ។

ដានីៈ តែនៅក្នុងវរៈគេហៅវរៈអីគេ?

ជួៈ ខ្ញុំវរៈសេនាតូច១២០ ។

ដានីៈ អញ្ចឹងអ៊ំនៅកន្លែងក្រាំងល្វាហ្នឹងរយៈពេលប៉ុន្មានទៅ?

ជួៈ ធ្វើការរហូត ដល់វ៉ៃឈ្នះភ្នំពេញឆ្នាំ៧៥ ។

ដានីៈ ប៉ុន្តែអង្គភាព១២០របស់អ៊ំហ្នឹងនៅក្រាំងល្វា ហើយនៅក្រាំងល្វារហូតឬក៏មានការផ្លាស់ប្តូរ អីទៀត?

ជួៈ ផ្លាស់ប្តូររហូត ។

ដានី៖ ផ្លាស់ទៅណាទៅ?

ជួ៖ មកមួយជួរ ចាប់ពីគគរទៅដល់ស្ពានសេដ្ឋានៅជិតភ្នំពេញហ្នឹង ហើយសារពីហ្នឹងមក មកដល់ត្រឹមគគរយើងទម្រាំតែរួចបកទៅវិញទៀត មួយឆ្នាំទៅដល់ស្ពានសេដ្ឋា ហើយបកពីហ្នឹងទៅគគរហ្នឹងមួយឆ្នាំ ។

ដានី៖ ដល់ឆ្នាំណាបានយើងបង្កើតកងពលទីមួយ?

ជួ៖ ប្រហែលជា៧២ហើយ ។

ដានី៖ ៧២?

ជួ៖ ប្រហែលជា៧១-៧២ហ្នឹងហើយ ។

ដានី៖ កងពលទី១ហ្នឹងមានសមាសភាពមកពីណាខ្លះ?

ជួ៖ សមាសភាពអ្នកដឹកនាំ គេហៅពេទ្យ សឿង ។

ដានី៖ ពេទ្យ សឿង?

ជួ៖ បាទ! តែគាត់ស្លាប់ហើយ ។

ដានី៖ គាត់ស្លាប់ពីអង្កាល់?

ជួ៖ ស្លាប់សម័យ៣ឆ្នាំ ។

ដានី៖ មូលហេតុអីបានជាគាត់ស្លាប់?

ជួ៖ ប្រហែលជាគាត់មានជម្ងឺ ខ្ញុំមិនសូវដឹងដែរ បែកគ្នាទៅ ។

ដានី៖ កាលហ្នឹងប្រធានកងពលឈ្មោះពេទ្យ សឿង?

ជួ៖ បាទ!

ដានី៖ ហើយចុះអ៊ំ សាន?

ជួ៖ អ៊ំ សាន គាត់អនុ ។

ដានី៖ អនុតា សឿង?

ជួ៖ បាទ!

ដានី៖ ហើយចុះអ៊ំកាលហ្នឹងអត់មានតួនាទីអីទេ?

ជួ៖ សម័យ៣ឆ្នាំ?

ដានី៖ អត់ទេ ។

ជួ៖ ធ្វើដែរ តែធ្វើកងតូចកងអីហ្នឹង ប្រធានក្រុមប្រធានអីកងតូចហ្នឹង ។

ដានី៖ អញ្ចឹងកាលហ្នឹងអ៊ំស្គាល់អ៊ំ សាន ច្បាស់ទេ?

ជួ៖ មិនស្គាល់ម៉េច បើមេខ្ញុំហើយហ្នឹង ។

ដានី៖ គាត់ឈ្មោះ សាន អញ្ចឹងរហូត?

ជួ៖ ឈ្មោះ កែវ សាន ។

ដានី៖ ហើយអ៊ំឈ្មោះ ឈាង ជួ អញ្ចឹងរហូត អត់មានឈ្មោះបដិវត្តន៍អីទេ?

ជួ៖ អត់មានទេ ។

ដានី៖ អញ្ចឹងអ៊ំកងពលទី១ យើងដើរធ្វើការនៅម្តុំណាខ្លះទៅ ដែលអ៊ំមានប្រសាសន៍មេញថានៅគគរ ខាងកំពង់លួងរហូតដល់ស្ពានសេដ្ឋា?

ជួ៖ កំពង់លួងខត្តុងហ្នឹង ពួកខ្ញុំសារចុះសារឡើងហ្នឹង ។

ដានី៖ រហូតដល់ឆ្នាំ៧៥ ប្តូរក៏មានផ្លាស់ទៅណា?

ជួ៖ ឆ្នាំ៧៥ហ្នឹង ឈ្នះភ្នំពេញហើយ គឺយកកងពលទី១ហ្នឹងមកបញ្ជូរជើងនៅបន្ទាយលវ៉ែក ណា ។

ដានី៖ កងពលទី១មកបន្ទាយលវ៉ែកទាំងអស់?

ជួ៖ បាទ! មកទាំងអស់ហើយបំបែកមួយចំនួនទៅជើងអាកាស?

ដានី៖ មួយចំនួនទៅជើងអាកាស?

ជួ៖ បាទ!

ដានី៖ ម៉េចអញ្ចឹង?

ជួ៖ ចុះមានមេមួយទៀតឈ្មោះ ស៊ូ ម៉េត ។

ដានី៖ អញ្ចឹង ស៊ូ ម៉េត គាត់នៅកងពលទី១ដែរ?

ជួ៖ បាទ!

ដានី៖ ដឹបូងនៅកងពលទី១ដែរ?

ជួ៖ បាទ!

ដានី៖ អញ្ចឹងនៅក្នុងកងពលនោះមាន តាសឿង, តាម៉េត ហើយតាសាន?

ជួ៖ បាទ!

ដានី៖ តាសាន គាត់គណៈកងពលហ្នឹង?

ជួ៖ បាទ!

ដានី៖ ជាមួយគ្នា?

ជួ៖ ហើយប៉ុន្មាននាក់នោះស្លាប់អស់ហើយ ។

ដានី៖ ហើយមានពីណាទៀត បើតាមអ៊ំចាំ?

ជួ៖ មានតាអ៊ំ សេរី តែគ្រកូលគាត់មិនដឹងឈ្មោះអីទេ ។

ដានី៖ គាត់ស្លាប់ពីអង្កាល់ទៅ?

ជួ៖ ស្លាប់កាលជំនាន់សង្គ្រាមហ្នឹង ។

ដានី៖ ជំនាន់សង្គ្រាមណាទៅ សង្គ្រាមពី៧០ដល់៧៥ឬក៏?

ជួ៖ ហ្នឹងហើយសង្គ្រាម៧៥ហ្នឹង ។

ដានី៖ អញ្ចឹងដល់ពេលបែកភ្នំពេញឆ្នាំ៧៥ កងពលទី១ហ្នឹងគេដកមកបន្ទាយលង្វែក ហើយគេមានបំបែកជាកងពលជើងអាកាសទៀត?

ជួ៖ មួយចំនួនទៅជើងអាកាស នៅពោធិ៍ចិនតុងណា ហើយគេដកឈ្មោះ ម៉េត ហ្នឹងទៅគ្រប់គ្រងខាងជើងអាកាសហ្នឹង គាត់សុំមួយចំនួនទៅជាមួយគាត់ ។

ដានី៖ អ៊ំស្គាល់គាត់ច្បាស់ទេ?

ជួ៖ ថឺមិនស្គាល់ ។

ដានី៖ គាត់ស្គាល់អ៊ំទេ?

ជួ៖ ស្គាល់ បើនៅជាមួយគ្នា ។

ដានី៖ នៅជាមួយគ្នា តែឥលូវបើទៅគាត់នៅស្គាល់អ៊ំទេ?

ជួ៖ នៅតែស្គាល់ហ្នឹង ។

ដានី៖ អញ្ចឹងទៅជាមួយ ស៊ូ ម៉េត ហ្នឹងប៉ុន្មាននាក់ទៅ?

ជួ៖ ទៅមួយវរៈសេនាធំ ។

ដានី៖ ហើយចុះក្រៅពីហ្នឹងទៀត?

ជួ៖ នៅជាមួយ តាសឿង នៅបន្ទាយលង្វែក ។

ដានី៖ ហើយចុះអ៊ំនៅជាមួយគាត់ដែរ?

ជួ៖ ខ្ញុំនៅលង្វែកដែរហ្នឹង ។

ដានី៖ ចុះអ៊ំ សាន?

ជួ៖ អ៊ំ សាន ក៏នៅលង្វែក ។

ដានី៖ ហើយកាលហ្នឹងអ៊ំតួនាទីអី?

ជួ៖ ខ្ញុំនៅតូចតាចហ្នឹង ។

ដានី៖ តូចតាចហ្នឹងគេហៅថានៈអីគេដែរ?

ជួ៖ កូនចៅកងតូចអីហ្នឹង ។

ដានី៖ ហើយចុះអ៊ំនៅលង្វែករហូតដល់ពេលណាទៅ?

ជួ៖ ខ្ញុំនៅដល់ឆ្នាំ៧៧ ។

ដានី: ហើយចុះនៅលង្វែកធ្វើអីខ្លះទៅ?

ជួ: នៅលង្វែកធ្វើស្រែធ្វើអីហ្នឹង ។

ដានី: ប៉ុន្តែនៅលង្វែកហ្នឹង នៅជាកងពលទី១ដដែលឬក៏មានផ្លាស់ប្តូរកងពល?

ជួ: នៅតែជាកងពលទី១ ហ្នឹង ។

ដានី: ចុះមួយចំនួនគេឲ្យទៅដើរអាកាសហើយ អញ្ចឹងកងពលទី១ ហ្នឹងវាមានកម្លាំងសល់តិច ឬក៏គេមានបញ្ចូលថ្មី?

ជួ: គេបញ្ចូលទៀត ។

ដានី: បញ្ចូលពីខាងណាមក?

ជួ: បញ្ចូលពីខាងតំបន់ខ្លះ ហើយមានពីស្រុកខ្លះ មកបង្គ្រប់ ។

ដានី: មកបង្គ្រប់បាន៣វរៈសេនាធំ?

ជួ: បាទ!

ដានី: អញ្ចឹង៣វរៈសេនាធំហ្នឹងនៅលង្វែកទាំងអស់ ឬក៏មានឈរជើងនៅកន្លែងណាខ្លះ?

ជួ: នៅលង្វែកហ្នឹងមាន២វរៈសេនាធំ ។

ដានី: ហើយមាននៅណាទៀត?

ជួ: ហើយវរៈសេនាធំទៅនៅកោះកុង ។

ដានី: ប៉ុន្តែអ៊ំនៅលង្វែកទេ?

ជួ: ខ្ញុំនៅលង្វែកទេ ។

ដានី: ហើយកងពលទី១ហ្នឹងជាកងពលរបស់មជ្ឈឹម?

ជួ: បាទ! កងពលទី១របស់ភូមិភាគ ។

ដានី: ភូមិភាគណាទៅ?

ជួ: ភូមិភាគរបស់បច្ចឹម ។

ដានី: អញ្ចឹងមិនមែនកងពលរបស់ភូមិភាគមជ្ឈឹមទេ?

ជួ: មិនមែនទេ ។

ដានី: តាសឿង ហ្នឹងគាត់នៅភូមិភាគបច្ចឹមទេ?

ជួ: បាទ! ភូមិភាគបច្ចឹម មានប្រធានភូមិភាគ ឈ្មោះ ចាន់ស៊ី ។

ដានី: ជូ ចេត ហ្នឹងមែន?

ជួ: មិនដឹងដែរ គេហៅ ចាន់ស៊ី ។

ដានី: កាលហ្នឹងគណៈភូមិភាគមានប៉ុន្មាននាក់?

ជួៈ មានតែ តាស៊ី ហ្នឹង ព្រោះខ្ញុំស្គាល់តែ តាស៊ី ហ្នឹង ។

ដានីៈ ហើយមានស្គាល់ តាប៉ាល់ទេ?

ជួៈ ថីមិនស្គាល់ អ៊ំប៉ាល់ ។

ដានីៈ អ៊ំប៉ាល់គាត់គណៈភូមិភាគដែរ?

ជួៈ បាទ! តែក្រោម ចាន់ស៊ី ទេ ។

ដានីៈ កាលហ្នឹងភូមិភាគនៅកន្លែងណា?

ជួៈ មន្ទីរភូមិភាគហ្នឹងនៅកន្លែងណាទេ ខ្ញុំភ្លាប់មិនបានដែរ កាលហ្នឹងខ្ញុំនៅតូចតាចណាស់ ។

ដានីៈ អញ្ចឹងអ៊ំនៅលង្វែកហ្នឹងរហូតដល់ឆ្នាំ៧៧?

ជួៈ បាទ!

ដានីៈ អញ្ចឹង តាម៉េត គាត់មកខាងអាកាសទៅក៏ដាច់ទៅ?

ជួៈ បាទ!

ដានីៈ ទ័ពអាកាសហ្នឹងកងពលលេខប៉ុន្មានទៅ?

ជួៈ ៥០២ ។

ដានីៈ ហើយកាលហ្នឹងម៉េចបានជាអ៊ំអត់បានមកខាងទ័ពអាកាសហ្នឹងគេ?

ជួៈ គេកំណត់យកត្រឹមវរៈសេនាធំ គេយកវរៈសេនាធំហ្នឹង១៥ឬ១៦ ។

ដានីៈ ហើយយកទៅប៉ុន្មាន,

ជួៈ យកទៅ១៧ ។

ដានីៈ អញ្ចឹង១៥-១៦នៅ?

ជួៈ បាទ!

ដានីៈ អញ្ចឹង តាសឿង ហ្នឹងគាត់នៅហ្នឹងរហូត?

ជួៈ នៅហ្នឹងរហូត ។

ដានីៈ ហើយចុះអ៊ំ សាន?

ជួៈ អ៊ំ សាន ក៏នៅហ្នឹង ។

ដានីៈ អញ្ចឹងអ៊ំនៅលង្វែកហ្នឹង ធ្វើស្រែធ្វើអី?

ជួៈ ធ្វើស្រែ ហើយលើកភ្លឺស្រែសម័យហ្នឹង ។

ដានីៈ ស្រែនៅម្តុំណាទៅ នៅលង្វែកហ្នឹង?

ជួៈ នៅម្តុំប៉ារ៉ា ហើយនៅម្តុំក្រាំងពន្លៃ នៅខត្តុងអីហ្នឹង ។

ដានីៈ ហើយមន្ទីរពេទ្យនៅជិតហ្នឹងដែរ?

ជួៈ មន្ទីរពេទ្យនៅលំផ្នែកហ្នឹងហ្នង ។

ដានីៈ មន្ទីរពេទ្យហ្នឹងជាមន្ទីររបស់កងពលឬក៏?

ជួៈ របស់កងពល ។

ដានីៈ ចុះដល់ពេលឆ្នាំ៧៧យ៉ាងម៉េចទៅ?

ជួៈ ៧៧គេដកខ្ញុំ ហើយមួយចំនួនទៀតទៅបំពេញទ័ព ទៅក្រចេះហ្នឹងផ្លាស់លេខកងពលហើយ កងពលមជ្ឈឹមគឺកងពលលេខ១១៧ ។

ដានីៈ អញ្ចឹងកងពលទី១ហ្នឹងផ្លាស់ហើយ?

ជួៈ គេដកមួយចំនួនណា៎ ។

ដានីៈ ប៉ុន្មានទៅ?

ជួៈ គេដកក្រុមខ្លះ កងពល កងវរយ កងវរៈអីខ្លះ វរៈសេនាធំខ្លះយកទៅផ្ញើកងពលមួយវរៈទៀត ហើយកងពល១៧៧ហ្នឹងដកពីតំបន់ ដកពីស្រុក ទៅតាំងពីភូមិភាគពាយ័ព្យ ។

ដានីៈ អញ្ចឹងដកតាំងពីភូមិភាគពាយ័ព្យ កងពលទី១ ហើយពីប៉ុន្មានខ្លះទៀត?

ជួៈ កងពលដកពីតំបន់៣១ តំបន់៣២ នៅកំពង់ស្ពឺខាងជើង ហើយតំបន់ពោធិ៍សាត់នេះ ភូមិភាគពាយ័ព្យនេះមួយចំនួន ម៉ាកងពល១១៧ហ្នឹងបំពាក់អាវុធ កាលវៀតណាមទាស់គ្នាតាមព្រំដែននោះ ។

ដានីៈ ឆ្នាំ៧៧?

ជួៈ បាទ!

ដានីៈ ចុះអ៊ឹ ភូមិភាគបច្ចិមហ្នឹងមានប៉ុន្មានតំបន់ តំបន់៣១នៅកំពង់ឆ្នាំង?

ជួៈ ហើយតំបន់៣២នៅកំពង់ឆ្នាំងខាងជើង ហើយតំបន់កំពង់សិលា ។

ដានីៈ កំពង់សិលានៅស្រែនៅអីហ្នឹង?

ជួៈ បាទ!

ដានីៈ អាហ្នឹងកំពង់ស្ពឺខាងជើង?

ជួៈ បាទ!

ដានីៈ ហើយមានតំបន់៣០ប៉ុន្មានទៀត?

ជួៈ មានតំបន់៣៧ តំបន់១១ ។

ដានីៈ តំបន់៣៧នៅណា?

ជួៈ នៅកំពង់សិលា ។

ដានីៈ អញ្ចឹងកំពង់សិលានៅតំបន់៣៧?

ជួ៖ បាទ!

ដានី៖ ចុះតំបន់១១?

ជួ៖ តំបន់១១នៅកោះកុង។

ដានី៖ អញ្ចឹងតំបន់៣១កំពង់ឆ្នាំង តំបន់៣២កំពង់ឆ្នាំងខាងជើង ហើយនៅកន្លែងណាខ្លះ?

ជួ៖ នៅម្តុំភ្នំស្រួចហ្នឹង អាជួរយើងគ្រពាំងខ្ទីងអីហ្នឹង។

ដានី៖ ដល់ពេលតំបន់៣៧?

ជួ៖ តំបន់៣៧នៅកំពង់សិលា។

ដានី៖ កំពង់សិលាខាងស្រែខាងអីវិញ?

ជួ៖ បាទ!

ដានី៖ ដល់ពេលតំបន់១១ខាងកោះកុង?

ជួ៖ កោះកុង។

ដានី៖ មានតែប៉ុណ្ណឹងទេ?

ជួ៖ មានតែប៉ុណ្ណឹង។

ដានី៖ តំបន់ខាងភូមិភាគបច្ចឹម?

ជួ៖ បាទ!

ដានី៖ ពេលហ្នឹងគេបង្កើតកងពលលេខ១១៧អញ្ចឹង?

ជួ៖ បាទ!

ដានី៖ ដែលគេជ្រើសរើសចេញមកមានខាងតំបន់កំពង់ឆ្នាំងមានអីហ្នឹង បញ្ចូលបានមួយកងពល?

ជួ៖ បាទ!

ដានី៖ ហើយកាលហ្នឹងដឹកនាំដោយពីណាគេ ពីណាគេប្រធានកងពល?

ជួ៖ ប្រធានកងពលឈ្មោះ រ៉ុំ។

ដានី៖ ហើយពីណាគេអនុប្រធាន?

ជួ៖ អនុប្រធានឈ្មោះ លៀង។

ដានី៖ អនុមានតែមួយទេ ក្រែងមាន២-៣ដែរ?

ជួ៖ កាលហ្នឹងមានតែ២នាក់ទេ។

ដានី៖ កាលហ្នឹងអ៊ំមានតួនាទីអីដែរ?

ជួ៖ ខ្ញុំឡើងតិចណាស់។

ដានី៖ ឡើងដល់វរៈណា?

ជួៈ	វរៈសេនាតូចហ្នឹង ។

ដានីៈ	អញ្ចឹងកាលហ្នឹងយើងបំពេញបានជាកងពលហ្នឹង មានគ្នាប៉ុន្មានទៅ?

ជួៈ	គ្នាបីពាន់នាក់ ។

ដានីៈ	មួយកងពលមានតែបីពាន់នាក់ទេ?

ជួៈ	បាទ! កងពលតូច ។

ដានីៈ	ចុះម៉េចបានជាគេបញ្ជូនមកក្រចេះវិញ?

ជួៈ	បញ្ជូនពីលផ្នែកទៅក្រចេះ បង្កើតកងពលថ្មីហ្នឹង ដើម្បីការពារតាមព្រំដែន ។

ដានីៈ	ព្រំដែននៅម្តុំណា?

ជួៈ	នៅម្តុំស្នួលហ្នឹង ។

ដានីៈ	នៅម្តុំស្នួលហ្នឹងហ្នង?

ជួៈ	ស្នួលមត់ហ្នឹង ហើយទៅទល់មណ្ឌលគិរីអញ្ចឹងទៅ ។

ដានីៈ	អញ្ចឹងទៅចាប់ដៃខាងតំបន់ ខាងភូមិភាគគណៈ?

ជួៈ	ចាប់ដៃជាមួយតំបន់ក្រចេះ៥០៥ហ្នឹង ។

ដានីៈ	ពីណាគេគ្រប់គ្រងនៅតំបន់ក្រចេះ?

ជួៈ	ក្រចេះ គណៈតំបន់គឺ យី គួន ។

ដានីៈ	កាលហ្នឹងនៅ យី គួន នៅឡើយទេ?

ជួៈ	បាទ!

ដានីៈ	អញ្ចឹងយើងទៅចាប់ជាមួយកងទ័ពខាងតំបន់ក្រចេះវិញ?

ជួៈ	បាទ!

ដានីៈ	កាលហ្នឹងយើងឈរជើងនៅតាមព្រំដែនហ្នង ឬក៏ទីក្រុងក្រចេះទេ?

ជួៈ	កងពលគេយកទៅដាក់នៅស្នួល ។

ដានីៈ	កាលហ្នឹងយើងវៃគ្នាយ៉ាងម៉េចទៅ បើព្រំដែន ពេលដែលយើងមានជម្លោះព្រំដែនជាមួយយួន ចាប់ផ្តើមពីឆ្នាំ៧៧ ដូចថាយើងចាប់ផ្តើមវៃគ្នាយ៉ាងម៉េចអីយ៉ាងម៉េច?

ជួៈ	ដូចថាគេចេះតែមកចូលដីយើង ។

ដានីៈ	មកចូលដីយើង?

ជួៈ	ហ្នឹងហើយ ដូចថាប្រជាពលរដ្ឋស្លូតវាមកដកសន្ទូងយើង មុនដំបូងចចារគ្នា របៀបដូចតែថៃអញ្ចឹង ដូចថៃយើងវៃគ្នាពល់ថ្ងៃអញ្ចឹង យើងចចារថាឈប់ហើយ ដល់ពេលថ្ងៃក្រោយយើងមកទៀត វាមកធ្វើយើងទៀត ជួនកាលមកលបបាញ់យើងហ្នង ។

ដានី៖ មកលបបាញ់យើងទៀត?

ជួ៖ បាទ!

ដានី៖ ចុះកាលហ្នឹងវរៈសេនាតូចរបស់អ៊ីនៅម្តុំណា?

ជួ៖ ខ្ញុំចាប់ពីថ្នល់១៣ចូលឃួនហ្នឹង ដែលគេហៅថាថ្នល់ជាតិលេខ១៣ចូលទៅឃួនណា៎ ទៅខាងកើតហើយធ្លុះទៅត្រពាំងស្បែកអញ្ចឹងទៅ ។

ដានី៖ នៅព្រំដែនហ្នឹងហ្មង?

ជួ៖ បាទ! ខ្ញុំនៅតែព្រំដែនទេ មិនដែលទៅណាទេ នៅក្នុងព្រៃរហូតហ្នឹង ខ្ញុំកងទ័ពមិនដែលស្គាល់ប្រជាពលរដ្ឋទេមួយឆ្នាំទល់មួយឆ្នាំ ។

ដានី៖ ចុះវៀយ៉ាងម៉េចដែរកាលហ្នឹង?

ជួ៖ វៀអញ្ចឹងទៅចាញ់ឈ្នះៗហ្នឹង ដល់ពេលឃួនវាចេះតែបង្កើនកងទ័ពវាច្រើនទៅៗ ហើយយើងមានស្អី មានតែប៉ុណ្ណឹង តែកងពលមួយបំប៉នអីខ្លះទៅ ហើយចេះតែថយៗទៅ គេកាន់តែច្រើនទៅៗ ។

ដានី៖ ហើយយើងចេះតែដកថយអញ្ចឹងទៅ?

ជួ៖ ត្រូវតែដកថយហើយ ព្រោះយើងទប់ជាមួយគេអត់បាន គេវាច្រើនពេក ។

ដានី៖ គេច្រើនពេក?

ជួ៖ បាទ!

ដានី៖ តែអ៊ីធ្លាប់វៀចូលដល់ក្រុងតេទេ?

ជួ៖ ចូលតិចៗហ្នឹង ។

ដានី៖ អញ្ចឹងកងទ័ពយើងគ្រាន់បើដែរចេះវៀចូលដល់ហ្នឹង?

ជួ៖ បានមួយប្រាវ ពីរប្រាវដំបូង ប៉ុន្តែយើងមិនទៅចង់បានទឹកដីគេទេ គ្រាន់ថាដេញឲ្យវាឆ្ងាយ ។

ដានី៖ ចូលដល់កន្លែងប្រជាជនវាដែរ?

ជួ៖ ដូចអត់ឃើញទេ ប្រជាជនវាជម្លៀសអស់ ឃើញតែផ្ទះសម្បែងហ្នឹង ។

ដានី៖ ហើយយើងអត់មានចាប់អីវាបានទេ?

ជួ៖ អត់ទេ ។

ដានី៖ ហើយចុះកងទ័ពវាពេលវៀចូលមក យើងអត់មានចាប់ទេ?

ជួ៖ កាលហ្នឹងកងទ័ពឃួនចូលមកស្រុកយើងក៏អត់មានឃើញចាប់អីដែរ ពេលដែលវៀគ្នា បាញ់គ្នាស្លាប់នៅហ្នឹងហ្មង ស្លាប់រៀងខ្លួនទៅ ។

ដានី:　　ស្លាប់រៀងខ្លួន?

ជួ:　　បាទ!

ដានី:　　ហើយវាក៏អត់មានចាប់ខាងយើងបានដែរ?

ជួ:　　បាទ! យើងជម្លៀសចេញព្រឹបៗដែរ គ្រាន់តែយួនមកដល់ស្វាយជ្រះ ពាក់ក្រចេះ ពាក់កណ្ដាលស្ទួលហ្នឹង ក្រចេះហ្នឹងជម្លៀសចេញបាត់អស់ហើយ ។

ដានី:　　យើងជម្លៀសចេញអស់ហើយ?

ជួ:　　បាទ! មាននៅអីមាននៅតែសំបកផ្ទះហ្នឹង ។

ដានី:　　ចុះក្រចេះកាលនោះប្រធានកងពលនៅណាដែរ?

ជួ:　　កងពលនៅជាមួយទ័ពហ្នឹង ។

ដានី:　　នៅជាមួយកងទ័ពដែរ?

ជួ:　　បាទ! ដល់ពេលហ្នឹងហើយលែងគិតទីស្នាក់ការ កងពលអីហើយ នៅតែជាមួយគ្នាហ្នឹង ។

ដានី:　　តារុំ គាត់អ្នកស្រុកណាដែរ?

ជួ:　　តារុំ អ្នកកំពត ។

ដានី:　　ហើយឥលូវគាត់នៅណាដែរ?

ជួ:　　បែកបាក់គ្នាអាគាត់អាតាយអស់ហើយ ។

ដានី:　　ចុះមួយទៀតឈ្មោះ តានៀង អញ្ចឹងមែនទេ?

ជួ:　　ឈ្មោះ តាលៀង ។

ដានី:　　តាលៀង គាត់នៅណា?

ជួ:　　តាលៀង ស្រុកគាត់នៅតាកែវ ។

ដានី:　　គាត់នៅរស់ទេ?

ជួ:　　អត់ដឹងទេ ។

ដានី:　　តាលៀង ហ្នឹងគាត់មកពីណា គាត់មកពីកងពលទី១ហ្នឹងដែរ?

ជួ:　　គាត់ចេញពីកងពលទី១ហ្នឹងដែរ ។

ដានី:　　ហើយ តារុំ ហ្នឹងកងពលទី១ដែរ?

ជួ:　　បាទ!

ដានី:　　ដកចេញពីគណៈកងពលមក?

ជួ:　　អត់ទេ ដកចេញពីវរៈសេនាធំ វរៈសេនាតូចហ្នឹងណា៎ ដល់ពេលឡើងទៅធ្វើកងពលទៅ ទៅវ៉ៃទៅ ។

ដានី៖ ចុះ តាសឿន អ៊ំសាន ហ្នឹង?

ជួ៖ ពួកគាត់មេចាស់ៗ ។

ដានី៖ មេចាស់ៗហ្នឹងគាត់នៅណា?

ជួ៖ គាត់នៅលង្វែកហ្នឹងមើលទៅ ។

ដានី៖ អ៊ំសាន គាត់ផ្លាស់មកខាងតំបន់វិញមែន?

ជួ៖ បាទ! គាត់ផ្លាស់ទៅតំបន់៣២ ។

ដានី៖ គាត់ផ្លាស់ទៅជាគណៈតំបន់៣២?

ជួ៖ កាលហ្នឹងមិនដឹងជាគាត់ទៅធ្វើអីទេ ដឹងតែគាត់ផ្លាស់ទៅតំបន់៣២ ។

ដានី៖ ឆ្នាំណា?

ជួ៖ ឆ្នាំ៧៨ ចុង៧៧ ។

ដានី៖ អញ្ចឹងគាត់មកខាងតំបន់៣២ ហើយអ៊ំទៅខាងក្រចេះ?

ជួ៖ បាទ!

ដានី៖ កាលហ្នឹងអ៊ំមានគ្រួសារនូវ?

ជួ៖ ខ្ញុំមានហើយ ។

ដានី៖ មានពីឆ្នាំណាមក?

ជួ៖ ខ្ញុំការឆ្នាំ៧៥ ។

ដានី៖ ឆ្នាំ៧៥ហ្នឹងអ៊ំការនៅណា?

ជួ៖ ការនៅលង្វែកហ្នឹង ។

ដានី៖ ហើយចុះអ៊ំស្រីគាត់ធ្វើអីដែរ បានជាអ៊ំជួបគាត់?

ជួ៖ គាត់ធ្វើខាងពេទ្យ ។

ដានី៖ គាត់នៅណា?

ជួ៖ ស្រុកកំណើតគាត់នៅស្ទួលហ្នឹង ។

ដានី៖ នៅស្ទួល ប៉ុន្តែពេលដែលអ៊ំជួបគាត់នៅលង្វែកហ្នឹង ជួបនៅកន្លែងណា?

ជួ៖ ខ្ញុំប្រពន្ធពីរហើយ ។

ដានី៖ អញ្ចឹងប្រពន្ធអ៊ំដែលជួបនៅលង្វែកគាត់ឈ្មោះអីដែរ?

ជួ៖ ហ្នឹងឈ្មោះ អែម ។

ដានី៖ ជួបគាត់នៅលង្វែក ហើយគាត់អ្នកស្រុកណាដែរ?

ជួ៖ គាត់អ្នកកំពង់ឆ្នាំង ។

ដានី: អញ្ចឹងឆ្នាំ៧៥ហ្នឹងអឺការជាមួយគាត់មួយសារ?

ជួ: បាទ!

ដានី: ហើយបែកគ្នាឆ្នាំណាទៅ?

ជួ: ឆ្នាំ៧៩ ។

ដានី: ៧៩ហ្នឹងបែកគ្នាយ៉ាងម៉េច?

ជួ: បែកហ្នឹងគេនៅក្រចេះ ហើយខ្ញុំនៅព្រំដែន ដល់ពេលអញ្ចឹងទៅគេជម្លៀសមកក្រោយៗហ្នឹង អាខ្ញុំមកភ្នំពេញ ដល់ពេលអញ្ចឹងទៅវាបែកអាគាត់អាគាយអស់ ហើយរកគ្នាអត់ឃើញ ។

ដានី: ដល់ឥលូវមានដែលជួបគ្នាទេ?

ជួ: គាត់ស្លាប់បាត់ហើយ ។

ដានី: គាត់ស្លាប់ពីអង្កាល់?

ជួ: គាត់ស្លាប់៥ឆ្នាំហើយ ។

ដានី: ហើយមានកូនជាមួយគាត់ប៉ុន្មាននាក់?

ជួ: មានមួយ ប៉ុន្តែស្លាប់ដែរហើយ ។

ដានី: ស្លាប់ដែរ?

ជួ: បាទ! ខ្ញុំទៅមកៗហ្នឹង ។

ដានី: ដល់ពេលក្រោយមកគាត់នៅណា?

ជួ: ដល់ពេលក្រោយមកគាត់ទៅស្រុកហ្នឹង ។

ដានី: គាត់ទៅស្រុកវិញ?

ជួ: បាទ! នៅព្រៃផ្តៅ ។

ដានី: ស្រុកអីគេអ៊ំ?

ជួ: ស្រុកជលសារថ្មីយើងនេះ ។

ដានី: ខាងណា ខាងខេត្តកំពង់ធំ ។

ជួ: អត់ទេ ខាងខេត្តកំពង់ឆ្នាំងយើងហ្នឹង ។

ដានី: ហើយពេលដែលបែកគាត់ ឆ្នាំណាបានអ៊ំរកគាត់ឃើញ?

ជួ: ទើបតែរកឃើញឥលូវហ្នឹង ដឹងដំណឹងឥលូវៗនេះហ្នឹង ប្រហែលជា២ឆ្នាំហ្នឹង ។

ដានី: អញ្ចឹងពេលដឹងដំណឹងហ្នឹងគាត់ស្លាប់បាត់ហើយ?

ជួ: ស្លាប់បាត់ហើយ ។

ដានី៖ អញ្ជឹង?

ជួ៖ បាទ! រាល់ថ្ងៃនៅតែប្អូនថ្លៃហ្នឹង ។

ដានី៖ អញ្ជឹងតាំងពីបែក៧៩មក អត់ដែលបានជួបមុខគ្នាទេរហូតដល់គាត់ស្លាប់?

ជួ៖ បាទ! គេយកគ្រួសារទៀតទៅ ។

ដានី៖ អញ្ជឹងអ៊ំយកគ្រួសារថ្មីទៀតឆ្នាំណា?

ជួ៖ ខ្ញុំយកឆ្នាំ៨១ ។

ដានី៖ ហើយចុះអ៊ំស្រីក្រោយ ជួបគាត់នៅណាទៅ?

ជួ៖ ជួបនៅព្រំដែនហ្នឹង ។

ដានី៖ គាត់អ្នកមកពីណា?

ជួ៖ គាត់អ្នកមកពីក្រចេះ ។

ដានី៖ ស្រុកកំណើតគាត់អ្នកក្រចេះ?

ជួ៖ បាទ! អ្នកស្នួល ។

ដានី៖ រត់មកជាមួយគ្នា ដល់ពេលឆ្នាំ៨១បានការជាមួយគាត់ទៅ?

ជួ៖ បាទ! រកនោះអត់ឃើញ ខ្ញុំដើររកដែរ រកតាមព្រំដែនតែរកអត់ឃើញ ហើយសម្រេចចិត្តថាឈប់រក នៅតែឯងម៉េចទេ ដូចវាឯតែលគោលណាស់ ។

ដានី៖ អញ្ជឹងពេលឆ្នាំ៧៩ហ្នឹង ពេលដែលយួនចូលមកអ៊ំរត់តាមណាអីតាមណាទៅ?

ជួ៖ ខ្ញុំចេញពីស្នួលមកឆ្លងទន្លេ ។

ដានី៖ ឆ្លងមកខាងព្រែកប្រសព្វ?

ជួ៖ ព្រែកប្រសព្វមកខាងម្តុំភូមិគរអីហ្នឹង ហើយកាត់ព្រៃមកខាងកំពង់ធំមកលើ ។

ដានី៖ តាមគគីតាំងរនេហ្នឹង?

ជួ៖ បាទ! តាមហ្នឹង ។

ដានី៖ តាមគគីតាំងរនេចាក់មកខាងកំពង់ធំវិញ?

ជួ៖ បាទ! កំពង់ធំកំពង់ថ្មហ្នឹង ។

ដានី៖ ហើយយ៉ាងម៉េចទៀតទៅ?

ជួ៖ ដល់ពេលអញ្ជឹងទៅថាឆ្លងថ្នល់ជាតិលេខ៦ហ្នឹង មកកំពង់ឆ្នាំង ហើយដល់ពេលពេញស្រុកអស់ទៅសៀវ ធ្លាក់ឯងទៅស្រយ៉ង់កោះកេរ ហើយធ្លាក់ទោះអន្លង់វែង ហើយទៅតាមជួរភ្នំដងរែក ហើយទៅដល់ប្រាសាទតាមាន់ ។

ដានី៖ ហើយទៅដល់ហ្នឹងឆ្នាំណា ទៅដល់ឆ្នាំ៧៩ហ្នឹងមែន?

ជួៈ បាទ! ឆ្នាំ៧៩ ។

ដានីៈ ទៅដល់ប្រាសាទក្របី នឹងប្រាសាទតាមាន់ហ្នឹង?

ជួៈ បាទ!

ដានីៈ កាលហ្នឹងអ៊ំ ទ័ពគេមកសមរភូមិទិសខាងណា?

ជួៈ មកពីក្រចេះមក ។

ដានីៈ ប៉ុន្តែយើងមកដល់ហ្នឹង មកដល់ខាងតាមាន់ ខាងតាក្របី ហើយខាងក្របីហ្នឹងកាលហ្នឹងខាងណាអ្នកគ្រប់គ្រង?

ជួៈ ខាងយើង ។

ដានីៈ ខាងយើងប៉ុន្តែដូចថាគេបែងចែកមុខសញ្ញាថាខាងនេះខាងនោះ ។

ជួៈ អាហ្នឹងខាងតំបន់គេនោះ តំបន់គេខុត្តមានជ័យហ្នឹង ។

ដានីៈ ហើយមានដែលបានជួប កែវ ពក ដែរទេ?

ជួៈ អត់ដែលបានជួបទេ ខ្ញុំអត់ដែលស្គាល់គាត់ផង ។

ដានីៈ អត់ដែលស្គាល់ កែវ ពក ទេ?

ជួៈ បាទ! ឮតែឈ្មោះហ្នឹង ។

ដានីៈ ហើយស្គាល់ឈ្មោះ តាប៉ូច ទេ?

ជួៈ អត់ទេ ។

ដានីៈ ហើយ តាអាន?

ជួៈ អត់ ខ្ញុំខាងភូមិភាគកណ្តាល ហើយគេភូមិខត្តរហ្នឹងអត់ដែលស្គាល់ទេ ។

ដានីៈ អញ្ចឹងមកដល់ប្រាសាទតាមាន់ហ្នឹង កងពលអ៊ំនៅដដែល?

ជួៈ យើងចេះតែដើរទេ ហើយកងពលគេនៅម៉ុំគេចេះតែការពារទៅ ចេះតែដើរទៅ ហើយសម្រាកនៅនេះ៣-៤យប់ទៅ ហើយចេះតែមកៗឆ្លងថ្នល់ជាតិលេខ៥ ដល់និមិត្តអូរជ្រៅប៉ោយប៉ែតហ្នឹង ។

ដានីៈ ដើរមកដាច់រយៈអង្គភាពហើយ អត់មាននៅជាមួយអង្គភាពទេ?

ជួៈ អង្គភាពនៅដដែល ។

ដានីៈ ប៉ុន្តែអ៊ំដើរហ្នឹង អ៊ំជារយៈកងទ័ពដើរជាមួយគ្នា ឬក៏ដើរតែឯង?

ជួៈ មកជាក្បួនកងទ័ពតែម្តង ។

ដានីៈ ដល់ពេលមកដល់និមិត្តអូរជ្រៅហើយយ៉ាងម៉េចទៀត?

ជូៈ មកហ្នឹង មកធ្វើការនៅម៉ិម៉ក់ហ៊ីន ធ្វើការនៅហ្នឹងមួយរយៈ ដល់ពេលអញ្ចឹងគេបញ្ជូនមកបារាំងធ្លាក់អីហ្នឹង មកបឹងឆ្នាំងនៅម៉ិដីថៃហ្នឹង ហើយចូលទៅវ៉ៃនៅប៉ៃលិន ហើយជាប់នៅប៉ៃលិនហ្នឹង កងពលចាស់ហ្នឹង ។

ដានីៈ កងពលរបស់អ្នកណាគេ?

ជូៈ កងពលរបស់ អ៊ី ឈាន ។

ដានីៈ ដល់ពេលមកដល់ប៉ៃលិន អ៊ំចូលកងពលជាមួយ អ៊ី ឈាន វិញ?

ជូៈ ក្រោយមកខ្ញុំមកនៅសំឡូត ។

ដានីៈ ចេញពីកងពលប៉ៃលិនមកនៅសំឡូតវិញ?

ជូៈ បាទ!

ដានីៈ ម៉េចអញ្ចឹង?

ជូៈ មកនៅជាមួយមេចាស់ តាម៉េត ហ្នឹង ។

ដានីៈ មកនៅជាមួយ តាម៉េត វិញ?

ជូៈ បាទ!

ដានីៈ កាលហ្នឹង តាម៉េត ហៅមកឬក៏មកខ្លួនឯង?

ជូៈ មកខ្លួនឯង ។

ដានីៈ អត់ចង់នៅជាមួយ អ៊ី ឈាន?

ជូៈ គាត់ទើបតែចេញមក ហើយមកគ្រប់គ្រង ។

ដានីៈ គាត់ចេញពីណាមក?

ជូៈ អ៊ី ឈាន គាត់នៅជាមួយ អៀង សារី ។

ដានីៈ អញ្ចឹងអ៊ំមកសំឡូតនៅឆ្នាំណា?

ជូៈ ប្រហែលជា៨២ហើយ ។

ដានីៈ អញ្ចឹង៨២មកសំឡូតវិញ?

ជូៈ បាទ!

ដានីៈ កាលហ្នឹងអ៊ំមានតួនាទីអីគេ?

ជូៈ ខ្ញុំអត់មានធ្វើអីទេ ខ្ញុំឈប់ហើយ ។

ដានីៈ ឈប់ម៉េច?

ជូៈ ឈប់ធ្វើអីហើយ ។

ដានីៈ អញ្ចឹងបានន័យថា ពេលអ៊ំនៅប៉ៃលិនអ៊ំនៅធ្វើកងទ័ពនៅឡើយ?

ជួៈ បាទ! នៅកងទ័ព ដល់ពេលក្រោយមកខ្ញុំឈប់ធ្វើហើយ ។

ដានីៈ ដល់ពេលអ៊ំមកនៅជាមួយ តាម៉េត នៅសំឡូត ។

ជួៈ គ្រាន់តែនៅជាមួយកងទ័ព តែមិនបានធ្វើអីទេ ។

ដានីៈ នៅជាមួយកងទ័ព តែអត់ដែលឡើងវៃឡើងអីទេ?

ជួៈ អត់ទេ យូៗជួយគេម្ដង ។

ដានីៈ អ៊ំនៅសំឡូតនៅម្ដុំណា?

ជួៈ នៅអូររថក្រោះ ។

ដានីៈ ម្ដុំណាអូររថក្រោះ?

ជួៈ ផ្ទះខ្ញុំនៅខាងជើងអាផ្លូវទៅបឡាងហ្នឹង ។

ដានីៈ ខាងជើងផ្លូវទៅបឡាងហ្នឹងហ្មង?

ជួៈ បាទ! ទៅពីផ្លូវបំបែកអូរឡុងទៅដីប្រហែលជា៥០០ម៉ែត្រហ្នឹង ប្រហែលជាដី១គីឡូហ្នឹង ។

ដានីៈ ទៅសំឡូត៤-៥ដងដែរហ្នឹង ហើយស្គាល់អូររថក្រោះច្បាស់ហ្នឹង ហើយមានស្គាល់ តាជន ដែរទេ ។

ជួៈ ស្គាល់ ។

ដានីៈ ហើយ តាទិត ស្គាល់ដែរ?

ជួៈ ស្គាល់ នៅហ្នឹងដែរ ខ្ញុំនៅសំឡូតទាល់តែគេហៅចាត់តាំងឲ្យមកនៅហ្នឹង ខ្ញុំមកនៅនេះ៩៦ ។

ដានីៈ អញ្ចឹងអ៊ំនៅសំឡូតតាំងពីឆ្នាំ៨២មក រហូតមកដល់ឆ្នាំ៩៥?

ជួៈ បាទ!

ដានីៈ នៅបានយូដែរអញ្ចឹង?

ជួៈ នៅបានយូ អាហ្នឹងអន្តរភាពដែលដកមកពីសំឡូតមក មកនៅហ្នឹង ហើយផ្ទះមួយជួរហ្នឹង ។

ដានីៈ ចុះម៉េចបានជាយើងចេញពីសំឡូតមកនៅហ្នឹង?

ជួៈ គេបំបែក ។

ដានីៈ ពីណាគេបំបែក?

ជួៈ ខាងខ្មែរក្រហមហ្នឹងគេបំបែក ។

ដានីៈ គេបំបែកយ៉ាងម៉េចទៅអ៊ំ?

ជួៈ បំបែកហ្នឹងគេរៀបចំមួយកងពលទៀតទៅ ។

ដានីៈ គេរៀបចំកងពលនៅហ្នឹងទៀត?

ជួៈ បាទ!

ដានី:	គេបំបែកម៉េច ឧបមាថាយើងនៅសំឡូតហើយគេចាត់តាំងឲ្យយើងមក?

ជួះ:	គេរៀបចំកងពលថ្មី ។

ដានី:	ប៉ុន្មាននាក់ទៅ?

ជួះ:	ដកពីនេះបន្តិច ដកពីនោះបន្តិច យើងមិនទាន់គ្រប់មួយកងពល នាមតែកងពលតែមនុស្សវាតិចដែរ ។

ដានី:	អញ្ចឹងកាលពីដំបូង កាលពីមុនឆ្នាំ៩០ដាងនៅហ្នឹងអត់មានកងពលអីទេ?

ជួះ:	អត់មានទេ ។

ដានី:	អត់មានមនុស្សរស់នៅទេអញ្ចឹង?

ជួះ:	មាន ។

ដានី:	មានមនុស្សរស់នៅដែរ តែកងពលអីអត់មានទេ?

ជួះ:	អត់ ។

ដានី:	អញ្ចឹងពេលអឹមកអញ្ចឹងបានគេបង្កើតកងពល?

ជួះ:	បាទ!

ដានី:	កងពលលេខប៉ុន្មានទៅ?

ជួះ:	កងពលហ្នឹងមាន គឹម ពៅ ។

ដានី:	កងពលហ្នឹងបង្កើតឆ្នាំ៩៥មែន?

ជួះ:	បាទ! ឆ្នាំ៩៥ ។

ដានី:	គឹម ពៅ គាត់មកពីខាងណាវិញ?

ជួះ:	មកពីសំឡូតដែរ ។

ដានី:	ចុះពីមុនឆ្នាំ៩៥នៅហ្នឹងអត់មានកងទ័ពអីនៅហ្នឹងទេ?

ជួះ:	នេះកងទ័ព កងពល បងយ៉ន់ ហ្នឹង ។

ដានី:	យ៉ន់ គឹមទីន ក្រុមប្រឹក្សាក្រុមហ្នឹង?

ជួះ:

ដានី:	ហ្នឹងកងពលគាត់នៅណា?

ជួះ:	នៅក្រពើរពីហ្នឹង គាត់ធ្វើការនៅហ្នឹង មុខសញ្ញាគាត់ដូវ៥៦ ។

ដានី:	ចុះខាង អៀង ដាន វិញ?

ជួះ:	អៀង ដាន ទៅនោះហ្នឹង ។

ដានី:	ទៅណា?

ជួ:	ជាប់ៗគ្នាអញ្ចឹងទៅ ។

ដានី:	ទៅខាងណា?

ជួ:	អៀង ដាន ទៅខាងម្ដុំមួងហ្នឹង ។

ដានី:	ចុះដូចថាកាលពីមុនដល់ពេលឆ្នាំ៨០ដាង តាសេង កងពលអីនៅណា?

ជួ:	អឺសេង គាត់ស្លាប់បាត់ហើយ ។

ដានី:	តែគាត់នៅខាងណា?

ជួ:	នៅមួយជួរជាប់ហ្នឹង ។

ដានី:	ចុះក្រែងកងពលហ្នឹងមានតាំងពី៨០មកមែន?

ជួ:	អានេះគ្រាន់តែថាជាមុខសញ្ញាកងពល យ៉ង់ ហ្នឹង ហើយកងពលខ្ញុំមកពីសំឡូតមកទើបតែបង្កើតថ្មីទេ ។

ដានី:	កងពល តាសេង ពេលដែល តាសេង ស្លាប់ទៅមានពីណាគេបន្តគាត់?

ជួ:	អឺសេង គាត់ដូចជាមួយ តាមុត អីហ្នឹង មេចាស់ៗ ។

ដានី:	មេចាស់ពីមុនមក ចុះអឺដល់ពេលមកហ្នឹង អឺមកធ្វើទាហានវិញទៀត?

ជួ:	ខ្ញុំនៅកន្លែងកងពលទេ ។

ដានី:	មកនៅកន្លែងកងពល ហើយមានតួនាទីអីគេ?

ជួ:	ធម្មតាហ្នឹង ។

ដានី:	ធម្មតាម៉េចទៅ?

ជួ:	យើងគ្រាន់តែគេចាត់ចែង ចែកអង្ករ ចែកអីហ្នឹងណ៎ា ។

ដានី:	អត់មានឋានៈកងពលទេ

ជួ:	អត់ទេ ដូចថាកងពលថាចែកអង្ករឲ្យទៅអង្គភាពនេះប៉ុណ្ណេះៗ ។

ដានី:	អញ្ចឹងមិនមែនអង្គភាពទេ ។

ជួ:	អត់ទេ តាពៅ ។

ដានី:	តែ តាពៅ ម្នាក់ឯងទេ?

ជួ:	ក្រោយមកគេរៀបចំមាន តាធំ ឈ្មោះ ឈៀម ធំ ខ្វាក់ភ្នែកមួយខាង ។

ដានី:	ចុះអឺកាលនៅសំឡូត កាលហ្នឹងយើងនៅយ៉ាងម៉េចទៅ នៅសំឡូតដូចថាស្រុះស្រួលគ្នាដែរ ឬក៏មានការបំបែកអីមកជាកងពលទៀត

ជួ:	នៅសំឡូតមានអី ស្រុះស្រួលគ្នាតើ ប៉ុន្តែក្រោយមកបំបែកឲ្យមកនៅវាលវែងនេះ ហើយឲ្យធ្វើការនៅកោះកុង ។

ដានី៖ គេបំបែកជាមុខសញ្ញាអញ្ចឹង?

ជួ៖ បាទ!

ដានី៖ ប៉ុន្តែយើងនៅសំឡូតក្រែងលយើងមានមុខព្រួញសេដ្ឋកិច្ចល្អជាងយើងនៅវាលវែង ពីចន្លោះ ៨០ ទៅ៩០ ?

ជួ៖ វាដូចតែគ្នាហ្នឹង តាមមុខតាមច្រករៀងៗខ្លួន ច្រកវាលវែងអញ្ចឹងច្រកថ្មដារ ។

ដានី៖ តែកាលពីមុន កាលពីឆ្នាំ៨០ អីហ្នឹងកាលនៅសំឡូតយើងមានត្បូងមានអី ។

ជួ៖ មាន នៅបឡាង នៅភ្នំពេជ្រអីហ្នឹង អាហ្នឹងយើងចាប់ផ្តើមធ្វើដែរហ្នឹង ទំរកដើម្បីចិញ្ចឹមគ្រួសារខ្លះអញ្ចឹងទៅ ។

ដានី៖ រកបានខ្លះដែរ?

ជួ៖ បាទ! រកបានខ្លះដែរកាលហ្នឹង ។

ដានី៖ ចុះកាលហ្នឹងដូចថាយើងរកអីបានខ្លះអញ្ចឹង គេបែងចែកឲ្យយើងមកនេះ យើងអត់មានទំនាស់អីទេ?

ជួ៖ អត់ទេ ស័គ្រចិត្តមក គេសួរថាកងពល តាពៅ ប្រធានកងពលឥលូវទៅនៅខាងតាម៉ោយ ហើយអ្នកអង្គភាព តាពៅ ហ្នឹងខ្លះក៏គេនៅនោះដែរហ្នឹង គេអត់មក ។

ដានី៖ ហើយ តាពៅ ហ្នឹងកាលយើងបំបែកមកពីប៉ៃលិនហ្នឹង កាលហ្នឹងមកជាមួយគាត់ដែរ?

ជួ៖ អត់ទេ គាត់នៅសំឡូតហ្នឹង ។

ដានី៖ ពីណាគេអ្នកចាត់ដូចថាឲ្យខាងអង្គភាព តាពៅ មកហ្នឹង?

ជួ៖ តាម៉េត ។

ដានី៖ អញ្ចឹងយើងចោលផ្ទះចោលដីនៅសំឡូតទៅ?

ជួ៖ ឲ្យទៅបងប្អូនទៅ គ្មានអីទេកាលនោះ ទៅកន្លែងណាដេកកន្លែងហ្នឹង ។

ដានី៖ ចុះត្បូង តាទិត គាត់អ្នកគ្រប់គ្រង?

ជួ៖ បាទ!

ដានី៖ ហើយកាលហ្នឹងរកស៊ីបានទេ?

ជួ៖ រកស៊ីបានណាស់ តាទិត តាដន អីហ្នឹង ។

ដានី៖ គាត់មានជាងគេ?

ជួ៖ មានណាស់ ។

ដានី៖ គាត់មានដោយសារគាត់អ្នកគ្រប់គ្រងត្បូងហ្នឹង?

ជួ៖ បាទ!

ដានី៖ តែត្បូងយើងគ្រប់គ្រងដើម្បីយកទ្រព្យមកផ្គត់ផ្គង់ទ័ពមែន?

ជួ៖ បាទ! ផ្គត់ផ្គង់ទ័ព បើអត់អ្នកកងទ័ពដូចខ្ញុំនេះ នៅហ្នឹងគ្មានអីហូប ហើយដូច គឹម ពៅ ហ្នឹងគ្មានអីទេ ។

ដានី៖ អញ្ចឹង?

ជួ៖ បាទ! អ្នកប្រយុទ្ធ ។

ដានី៖ អ្នកប្រយុទ្ធហ្នឹងស្រេចតែគេបែងចែកទេ?

ជួ៖ បាទ!

ដានី៖ ប៉ុន្តែយើងកងទ័ពយើងអាចទៅជីកទៅអីបានដែរ គេអត់មានហាមឃាត់យើងទេ?

ជួ៖ កាលហ្នឹងអត់មានហាមឃាត់ទេ ។

ដានី៖ ចង់ជីកចង់អីបានដែរ?

ជួ៖ បាទ! ទៅបាន ។

ដានី៖ តែអ៊ំមានធ្លាប់ជីកបានទេ?

ជួ៖ ធ្លាប់ជីកបានខ្លះដែរ ដល់ពេលមកនៅនេះឈប់ហើយ ។

ដានី៖ ដល់ពេលអ៊ំមកនៅនេះអ៊ំធ្វើអីទៅ?

ជួ៖ អត់មានធ្វើអីទេ នៅជាមួយ គឹម ពៅ ។

ដានី៖ នៅជាមួយ គឹម ពៅ ប៉ុន្តែយើងចាប់ផ្តើមធ្វើស្រែធ្វើចំការតាំងពីអង្កាល់មកដែរ?

ជួ៖ ឆ្នាំ២០០០ ។

ដានី៖ អញ្ចឹងពេល៩៥មកយើងអត់ទាន់ធ្វើទេ?

ជួ៖ អត់ទេ គ្រាន់តែកាប់ចំការខ្លះដែរ គ្រាន់តែដាំបន្លែអីហូបហ្នឹងណា៎ ព្រោះកាលហ្នឹងយើងនៅមានរបបបើកអង្ករបើកអីខ្លះៗ ។

ដានី៖ ហើយដូចខាងវាលវែង អ៊ំណាគាត់ជាអ្នកទទួលខុសត្រូវ អ្នកត្រួតពីលើ ដូចថាតាអៀងសារី តាខៀវ សំផន អ្នកមកទទួលខុសត្រូវខាងតំបន់ ដូចតា អៀង សារី គាត់ទទួលខុសត្រូវនៅខាងប៉ៃលិន ម៉ាឡៃ ហើយនៅខាងសំពៅលូន ភ្នំព្រឹក តាសុន សេន ជាអ្នកទទួលខុសត្រូវ ហើយនៅខាងអន្លង់វែងមានតាម៉ុក អញ្ចឹងណា៎ ហើយខាងយើងនេះខាងណាជាអ្នកទទួលខុសត្រូវ?

ជួ៖ ខាងយើងពីមុនមកមានតាទី១ ។

ដានី៖ តាប៉ុល ពត?

ជួ៖ បាទ!

ដានី៖ ដល់ក្រោយមក?

ជួ៖ ដល់ក្រោយមកប្រគល់ឲ្យ តានួន តែគ្នាគាត់ទាំងអស់ហ្នឹងទៅមកៗហ្នឹង ។

ដានី៖ ហើយចុះអ៊ំស្គាល់គាត់ច្បាស់ទេ?

ជួ៖ ស្គាល់តាមរូបថតដែរទេ ។

ដានី៖ ហើយដែលជួបនិយាយជាមួយគាត់ទេ?

ជួ៖ អត់ទេ ។

ដានី៖ ហើយអ៊ំបានជួបជាមួយ អ៊ំសាន នៅឆ្នាំណា?

ជួ៖ ជួប អ៊ំសាន នៅឆ្នាំ៧០ ។

ដានី៖ និយាយពេលដែលជួបក្រោយ ពេលដែលយើង?

ជួ៖ មកនៅនេះ?

ដានី៖ បាទ!

ជួ៖ មកនៅនេះឆ្នាំ៩៩ ។

ដានី៖ គាត់មកពីខាងណាវិញ?

ជួ៖ គាត់មុខសញ្ញាគាត់នៅក្នុង នៅរមាំងស មុំយើង ។

ដានី៖ នៅជាមួយ កែវ ពង់ អីហ្នឹង?

ជួ៖ បាទ! នៅជាមួយ កែវ ពង់ ។

ដានី៖ ដល់ពេលហើយបានគាត់មកវិញ?

ជួ៖ គេរៀបចំឲ្យមកនៅភូមិចាស់មួយ នៅជិតជ្រៃ ។

ដានី៖ គាត់អត់ចូលទៅធ្វើជាមួយខាងរាជរដ្ឋាភិបាលទេ កែវ ពង់ សាមារណកម្មហើយគាត់ធ្វើកងទ័ព?

ជួ៖ ព្រោះគាត់ចាស់ហើយ ។

ដានី៖ ចុះអ៊ំដល់ពេលសាមារណកម្មហើយ អ៊ំអត់មានធ្វើការងារអីទៀតទេ?

ជួ៖ ខ្ញុំធ្វើតើ ។

ដានី៖ ធ្វើអីគេ?

ជួ៖ ខាងធម្មការ ។

ដានី៖ ឥលូវហ្នឹងធ្វើការ?

ជួ៖ ខ្ញុំអាត្រែតហើយ ។

ដានី៖ អញ្ចឹងកាលពីសាមារណកម្មហើយអ៊ំនៅធ្វើអីគេ?

ជួ៖ ធ្វើធម្មការហ្នឹង ។

ដានី៖ ការិយាល័យធម្មការ?

ជួ៖ បាទ!

ដានី៖ អ៊ំធ្វើនៅឆ្នាំណា កន្លែងធម្មការហ្នឹង?

ជួ៖ តាំងពីសាមារណេកម្មមក ។

ដានី៖ រហូតដល់ពេលណា?

ជួ៖ រហូតដល់ចប់ ឆ្នាំ៩៩ ។

ដានី៖ អញ្ចឹង៩៩ចាប់ផ្ដើមធ្វើ?

ជួ៖ បាទ!

ដានី៖ ធ្វើដល់ពេលណា?

ជួ៖ ឈ្មោះខ្ញុំអាត្រែតតាំងពីឆ្នាំ២០០៦ ។

ដានី៖ ២០០៦ តែអ៊ំនៅធ្វើការរហូតដល់?

ជួ៖ រហូតដល់ដែលគេហៅថាកិច្ចសន្យានោះណា៎ ។

ដានី៖ ហើយឥលូវនៅ?

ជួ៖ ផ្ដាច់ហើយ ។

ដានី៖ តែអ៊ំនៅទទួលប្រាក់បៀវត្សដែរ?

ជួ៖ ទទួលរាល់ខែ ។

ដានី៖ ចុះគ្រួសារអ៊ំ?

ជួ៖ គ្រួសារខ្ញុំធ្វើស្រែ ធ្វើដែរធ្វើកាកបាទស័គ្រចិត្តហ្នឹង ព្រោះអត់ដែរ មានលុយមកពីណា ពេលកាកបាទគេមកទៅគេត្រូវការចែកចាយទៅជួយចែកចាយគេអញ្ចឹងទៅ ។

ដានី៖ ចុះអ៊ំរាល់ថ្ងៃនេះអ៊ំដែលឮពត៌មានទាក់ទងនឹងតុលាការគេបង្កើតឡើងដើម្បីជំនុំជំរះទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដូចថា តាមដែលអ៊ំធ្លាប់ស្គាល់គាត់ ដូចជាតានួន ជា, តាអៀង សារី, តាខៀវ សំផន ហើយនឹងអ្នកដែលគេជំនុំជំរះហើយអញ្ចឹងណា៎ មានលេខ០០២ ហើយនឹងលេខ០០១ ឌុច កាំង ហ្គេកអ៊ាវ ហៅឌុច អ៊ំដែលស្គាល់ ឌុច ទេ?

ជួ៖ អត់ដែលស្គាល់ទេ ។

ដានី៖ ចុះអ៊ំដែលធ្លាប់តាមដានពត៌មានហ្នឹងទេ ទាក់ទងហ្នឹងតុលាការហ្នឹង?

ជួ៖ មិនសូវដែលបានតាមដានទេ ។

ដានី៖ តែអ៊ំដឹងដែរថា០០២ហ្នឹង មានតាៗហ្នឹង?

ជួះ ដឹង ។

ដានី៖ ចុះចំពោះអ៊ំផ្ទាល់ ដែលអ៊ំធ្លាប់ឆ្លងកាត់ហើយធ្លាប់ដឹងរឿងមកថាតាៗអីអញ្ចឹងណា៎ តើអ៊ំយល់ឃើញថាការបង្កើតសាលាក្តីខ្មែរក្រហមឡើងដើម្បីជំនុំជំរះទោសហ្នឹងត្រឹមត្រូវដែរឬក៏មិនត្រឹមត្រូវទេ បើតាមការយល់ឃើញរបស់អ៊ំ?

ជួះ៖ គេរៀបចំហ្នឹងសុទ្ធតែត្រឹមត្រូវហើយ មិនមែនទៅកាប់សម្លាប់អី គ្រាន់តែថាពេលណាចាស់ជរាហើយ ខ្ញុំជឿថាខ្មែរក្រហមនៅកាន់កាប់រហូតហ្នឹង មានអ្នកណាទៅថ្កល់ទោសកើត ។

ដានី៖ បាទ! តែខ្មែរក្រហមនៅកាន់អំណាចមានតុលាការណាទៅនេះបាន ។

ជួះ៖ មានតុលាការណាជួយ ហើយកាលណាចាញ់គេហើយគឺ ។

ដានី៖ ប៉ុន្តែអ៊ំអត់យល់ឃើញថាអ្នកផ្សេងទេៗដែលគេកាន់ដែរម៉េចគេអត់កាត់ទោសគាត់ ដូចជាលន់ នល់ ហើយដូចជាអ្នកមុនៗមក ដល់ពេលគាត់ដួលរលំទៅមិនដែលឃើញគេបង្កើតតុលាការអញ្ចឹង ម៉េចបានជាគេបង្កើតតែតុលាការកាត់ទោសអ្នកសម័យ៣ឆ្នាំអញ្ចឹង?

ជួះ៖ រឿងហ្នឹងដូចមិនយល់ដែរហ្នឹង ខ្ញុំចេះតែឆ្ងល់ដែរ កាត់ទោសតែខ្មែរក្រហម តែរដ្ឋាភិបាលលន់ នល់ អត់និយាយ បើកាត់ទោសមានតែកាត់ទាំងអស់ ។

ដានី៖ បើតាមយោបល់អ៊ំ អ៊ំគិតថាមានតែកាត់ទោសទាំងអស់?

ជួះ៖ បាទ! ចុះបើសុទ្ធតែសម្លាប់ស្លាប់ប្រជាជនដូចតែគ្នាហ្នឹង វៀត្នាហើយមានតែងាប់ ហើយខាងរដ្ឋាភិបាលលន់ នល់ ក៏ងាប់ ហើយខាងរំដោះខ្មែរក្រហមហ្នឹងក៏ងាប់ ហើយអាមេរិចកាំងទម្លាក់គ្រាប់បែកអត់កាត់ទោសផង អាហ្នឹងវាពិបាកដែរដល់ពេលអញ្ចឹង ហើយកាត់ទោសតែម្ខាងអញ្ចឹង ។

ដានី៖ អ៊ំយល់ថាអត់ត្រឹមត្រូវទេអញ្ចឹង?

ជួះ៖ អាហ្នឹងប្រហែលជាមិនត្រឹមត្រូវទេ បើកាត់មានតែកាត់ទាំងអស់ អាមេរិចទម្លាក់គ្រាប់បែកនៅស្រុកខ្មែរយើងប៉ុន្មាន បេ៥២ ។

ដានី៖ អ៊ំមានដែលឃើញអាមេរិចកាំងទម្លាក់គ្រាប់បែកត្រូវមនុស្សស្លាប់យ៉ាងម៉េចទេ?

ជួះ៖ កាលនៅវៃងាប់ ហើយបាក់ផ្ទះប្រជាជនទាំងភូមិៗណា៎ ហើយកាលខ្ញុំនៅធ្វើការកំពង់ឆ្នាំងហ្នឹងងាប់តែប្រជាជនទេ កងទ័ពដែលត្រូវស្អី ។

ដានី៖ ងាប់តែប្រជាជន?

ជួះ៖ បាទ! ងាប់តែប្រជាជនទេ ។

ដានី៖ តែតាមពិតអាមេរិចកាំងថាទម្លាក់លើទាហានខ្មែរក្រហមទេ ។

ជួៈ ទម្លាក់លើតាហានខ្មែរក្រហមស្អី តាហានខ្មែរក្រហមនៅវិញគ្នានៅថ្នល់ជាតិ ដែលហ៊ានទម្លាក់ណា សាកទម្លាក់មើលមិនត្រូវគ្នាវាឥលូវហ្នឹង ។

ដានីៈ អញ្ចឹងតាមអ៊ំ អ៊ំថាកាត់ទោសអាមេរិចដែរ?

ជួៈ បាទ!

ដានីៈ អ៊ំខ្ញុំដូចជាអស់សំនួរអីត្រូវសួរអ៊ំទៀតហើយ អញ្ចឹងអ៊ំមានអីចង់បន្ថែមនៅអ្វីដែលខ្ញុំមិនបានសួរអ៊ំទេ?

ជួៈ ខ្ញុំដូចជាអត់មានអីទេ ដូចថាអស់ហើយ ហើយជាចុងក្រោយគ្រាន់ចង់ប្រាប់ថាកុំកាត់តែខ្មែរក្រហម កាត់ទាំងអស់ទៅ អ្នកដែលពាក់ព័ន្ធទៅហ្នឹងសង្រ្គាម៥ឆ្នាំហ្នឹង ។

ដានីៈ អញ្ចឹងខ្ញុំសូមអរគុណពូច្រើន ។

ជួៈ បាទ!

**«ចប់»**